ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

# កំណត់ហេតុ
# កិច្ចប្រជុំពិនិត្យ និងពិភាក្សា
# ស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃចន្ទ ប្រាំពីរកើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបបួន ត្រូវនឹងថ្ងៃទីម្ភៃមួយ ខែធ្នូ ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោងពីរ រសៀល នៅសាលប្រជុំ អាគារ ៩ ទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិនិត្យ និងពិភាក្សា ស្តីពី វឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន **អចិន្ត្រៃយ៍** គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម កើត សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ **ឯកឧត្តម ហ៊ូ ទុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **លោកជំទាវ សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា **ឯកឧត្តម មុំ ប៊ុនថន** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **លោកជំទាវ ឡុង សុផល្លី** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី **លោកជំទាវ ឧត្តមសេនីយ៍ទោ ប៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ **ឯកឧត្តម ប៉ែន ពេជ្រសាលី** អគ្គនាយក ក្រសួងយុត្តិធម៌ **ឯកឧត្តម វ៉េង ហឿង** អគ្គនាយក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ **លោក ជ័យ រដ្ឋា** ប្រធាននាយកដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គលេខាធិការរង អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត **សរុបចំនួន ២៤រូប ស្រី ៩រូប ។**

ជាកិច្ចចាប់ផ្តើម នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន **អចិន្ត្រៃយ៍** គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង លោក លោកស្រីប្រធាន អនុប្រធាននាយកដ្ឋាន និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលចំណាយពេលវេលាចូលរួមក្នុងកិច្ចប្រជុំនាឱកាសនេះ ។ លោកជំទាវ ប្រធានអង្គប្រជុំបានមានប្រសាសន៍ថា ការជួបប្រជុំគ្នាលើកនេះ គឺជាការត្រៀមដើម្បីធ្វើការឆ្លើយតបទៅនឹងអនុសាសន៍របស់សហរដ្ឋអាមេរិក និងតាមដានវឌ្ឍនភាព នៃការអនុវត្តផែនការការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆ្នាំ២០២០ កន្លងមកនេះ ដែលយើងនឹងត្រូវជួបនាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ខាងមុខនេះ ។ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ យើងបាន

ជួបគ្នាជាអន្តរក្រសួង/ស្ថាប័ន ជាមួយស្ថានទូតអាមេរិក ដែលយើងមានរបាយការណ៍មួយចំនួន និងមានការត្រៀមលក្ខណៈដើម្បីឆ្លើយតបទៅនឹងការចង់បានដែលមាននៅក្នុងអនុសាសន៍ទាំង១៧ចំណុច តែបើយើងមិនបានអនុវត្តទៅតាមផែនការទេ ចំណាត់ថ្នាក់យើងនឹងធ្លាក់ទៅលេខ៣ គឺជាឧបសគ្គដែលឈានទៅដល់ការប៉ះពាល់ទៅនឹងស្ថានភាពមួយចំនួន ដែលអាចហៅបានថាជាការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ទោះបីជាយ៉ាងណាក៏យើងមិនចង់បានករណីនេះផងដែរ ។ បន្ទាប់មក **លោកជំទាវ** បានលើកឡើងអំពីអនុសាសន៍ទាំង៥ ដែលយើងបានធ្វើការជ្រើសរើសមកបង្ហាញ ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័ន ដើម្បីធ្វើជារបាយការណ៍ពាក់ព័ន្ធលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមមាន៖ **ទី១.**អនុវត្តប្រព័ន្ធសម្រាប់តាមដានប្រមូលទិន្នន័យ និងរាយការណ៍ទិន្នន័យស្ដីពី កិច្ចប្រឹងប្រែងក្នុងការផ្តន្ទាទោសអំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ព្រមទាំងចែកផ្សាយទិន្នន័យក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ក្នុងរបៀប នៃការការពារអត្តសញ្ញាណ និងឯកជនភាពរបស់ជនរងគ្រោះ ។ **ទី២.** ផ្តល់សមត្ថកិច្ចឲ្យប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ សម្រាប់ប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស ។ **ទី៣.** ពង្រឹងកិច្ចប្រឹងប្រែងសម្រាប់ការអនុវត្តពេញលេញទូទាំងប្រទេស នូវពិធីសារសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះបឋម ក្នុងចំណោមក្រុមជនងាយរងគ្រោះ និងបណ្តុះបណ្តាលមន្ត្រីអំពីរបៀបអនុវត្ត ។ **ទី៤.** បង្កើនការចុះអធិការកិច្ចការងារដោយមិនជូនដំណឹងជាមុន ក្នុងប្រភេទការងារដែលមានភាពងាយរងគ្រោះខ្ពស់ ជាពិសេសការងារនៅក្នុងសិប្បកម្មឡឥដ្ឋ នេសាទ កសិដ្ឋានដាំដុះ ដោយផ្តោតលើការកំណត់ដែលជាប់ជំពាក់ ។ **ទី៥.** បង្កើនការធ្វើអធិការកិច្ច និងពិនិត្យមើលស្ថាប័នប្រាក់កម្ចី រួមទាំងអង្គការមីក្រូហិរញ្ញវត្ថុឯកជន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយបំណុលបង្ខិតបង្ខំក្នុងចំណោមសហគមន៍ដែលមានភាពទន់ខ្សោយផ្នែកសេដ្ឋកិច្ច ។ **លោកជំទាវ** ប្រធានអង្គប្រជុំក៏បានលើកឡើងអំពីអនុសាសន៍ទាំង១៧ចំណុច ដែលស្ថានទូតអាមេរិកបានផ្ញើមករាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាកិច្ចការត្រូវអនុវត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសគឺក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។ **លោកជំទាវ** បានបញ្ជាក់ថា ចំណុចទាំង៥ ខាងលើដែលបានជ្រើសរើស ត្រូវគប្បីធ្វើឲ្យបានច្បាស់លាស់ និងឲ្យទាន់ពេលវេលាកំណត់របស់អាមេរិក គឺគិតត្រឹមខែមីនា បើហួសការកំណត់នេះគឺមិនយកជាការទេ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ បានស្នើឲ្យឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមកិច្ចប្រជុំពិភាក្សានេះ លើកឡើងអំពីការងារដែលបានអនុវត្តកន្លងមក ដើម្បីធ្វើជារបាយការណ៍ និងធ្វើការឆ្លើយតបទៅនឹងអនុសាសន៍របស់សហរដ្ឋអាមេរិក ។ **លោកជំទាវ** តើយើងបានធ្វើអ្វីខ្លះបន្ទាប់ពីយើងបានជួបគ្នានៅខែកញ្ញាកន្លងមក?

**លោកជំទាវ ស៊ឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ការបង្ការទប់ស្កាត់ហាក់បីដូចជាមិនពាក់ព័ន្ធក្នុងចំណោមចំណុចទាំង៥ ដែលបានជ្រើសរើស អ្វីដែលមានការពាក់ព័ន្ធទៅនឹងការងារបង្ការ

ទប់ស្កាត់ដែលក្រុមការងារក្រសួងអប់រំទទួលខុសត្រូវ គឺចំណុចទី១៦ និងចំណុចទី១៧ ។ ដូច្នេះ ពាក់ព័ន្ធនឹងក្រុមការងារបង្ការទប់ស្កាត់ដែលមានក្រសួងអប់រំយុវជន និងកីឡាជាអ្នកដឹកនាំ សូមសួរទៅលោកជំទាវប្រធានអង្គប្រជុំ និងសមាជិក សមាជិកា នៃអង្គប្រជុំ ត្រូវធ្វើជារបាយការណ៍ជូនដែរឬទេដើម្បីបញ្ចូលទៅនឹងការឆ្លើយតបជាមួយសហរដ្ឋអាមេរិក? **លោកជំទាវ** បានលើកឡើងអំពីការបោះពុម្ពសៀវភៅសិក្សាក្នុងការដាក់បញ្ចូលមេរៀន ស្តីពីការងារបង្ការទប់ស្កាត់ នៃអំពើជួញដូរមនុស្ស ក៏ដូចជាការធ្វើចំណាកស្រុកក្រៅប្រទេសដោយសុវត្ថិភាព ទៅក្នុងកម្មវិធីសិក្សា ដើម្បីធ្វើការផ្សព្វផ្សាយទៅដល់សិស្សានុសិស្ស ពាក់ព័ន្ធនឹងការបោះពុម្ពសៀវភៅនេះគឺ ក្រសួងបានជួបប្រជុំក្រុមការងារជំនាញទាំងដៃគូជាតិ និងអន្តរជាតិដើម្បីធ្វើការកំណត់នូវគោលបំណង និងទិសដៅក្នុងការបញ្ចូលកម្មវិធីសិក្សាឲ្យបានពេញលេញគ្រប់កម្រិតទាំងអស់ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈទាំងរដ្ឋ និងឯកជន ត្រង់ចំណុចនេះផងដែរ តើក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ ដែរឬទេ? **លោកជំទាវ** បានបញ្ជាក់ថា ដោយសារការរីករាលដាល នៃជំងឺកូវីដ១៩ ធ្វើឲ្យមានការរាំងស្ទះដល់ដំណើរនេះមួយចំនួនផងដែរ ដូច្នេះតម្រូវឲ្យមានការផលិតមេរៀនជាលក្ខណៈអនឡាញ និងមានការបណ្តុះបណ្តាលគ្រូផងដែរ ទាក់ទងទៅនឹងមេរៀនប្រឆាំងការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពនេះ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ ចំពោះការអនុវត្តការងារ និងរបាយការណ៍ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺយើងផ្អែកលើយុទ្ធសាស្ត្រទាំង៤ ចំពោះការងារបង្ការទប់ស្កាត់ គឺជាបញ្ហាសំខាន់ដែលត្រូវតែធ្វើចាំបាច់ ។ **លោកជំទាវ** បានថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបោះពុម្ពសៀវភៅសិក្សាពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ២ កម្រិតរួចមកហើយ ព្រោះជាយុទ្ធសាស្ត្រមួយសំខាន់ តែសហរដ្ឋអាមេរិក មិនផ្តោតលើការងារបង្ការទប់ស្កាត់នេះទេ គេផ្តោតសំខាន់លើលទ្ធផលជាក់ស្តែង ។

**ឯកឧត្តម កេច សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ចំពោះអនុសាសន៍ទាំង៥ចំណុចដែលលោកជំទាវ បានលើកឡើង គឺមាន២ ចំណុចពាក់ព័ន្ធក្រសួងយុត្តិធម៌ ។ **ឯកឧត្តម** បានបង្ហាញអំពីវឌ្ឍនភាពដែលមាននៅក្នុងត្រីមាសទី៤ នៃឆ្នាំ២០២០ នេះ ជូនលោកជំទាវ ដាក់ទៅក្នុងរបាយការណ៍រួម កាលពីអំឡុងខែកញ្ញា ក្រោយពីបានជួបជាមួយទូតអាមេរិកហើយ លោក ល្វីសសាឡា ដែលជាអ្នកធ្វើរបាយការណ៍ជួញដូរមនុស្សទូទាំងពិភពលោក បានសួរមកក្រសួងយុត្តិធម៌ ថា បានដោះស្រាយ និងបញ្ជូនទិន្នន័យទៅគេហើយនៅ? **ឯកឧត្តម** បានឆ្លើយតបថា (មាន) តើលោកចង់បានត្រឹមថ្ងៃខែឆ្នាំណា? យើងបានជួបគាត់ ដើម្បីពន្យល់អំពីតារាងទិន្នន័យរឿងក្តីដែលមាន២ដំណាក់កាល ព្រមទាំងពន្យល់គាត់លម្អិតអំពីចំនួនរឿងក្តីផងដែរ ទាំងជនរងគ្រោះ និងជនល្មើស ។ **ឯកឧត្តម** បានបញ្ជាក់ថា ពីមុនក្រសួងយុត្តិធម៌ ពាក់ព័ន្ធនឹងប្រព័ន្ធតុលាការនៅមានបញ្ហាស្មុកស្មាញបញ្ហាបច្ចេកទេស តែឥឡូវនេះ គឺមិនមានបញ្ហាដូចមុនទេបន្ទាប់ពីមានការកំណែទម្រង់ប្រព័ន្ធតុលាការ និងបច្ចេកទេសដោយធ្វើការដោះស្រាយសំណុំរឿងកកស្ទះតាមបណ្តារាជធានី ខេត្តរួចមក ហើយទិន្នន័យពាក់ព័ន្ធដំណោះស្រាយក្នុងក្តីរបស់តុលាការ គឺអាចផ្តល់ជូនបានតាមការស្នើសុំរបស់ក្រុមការងាររបាយការណ៍គណៈកម្មាធិការជាតិ ដោយគ្រាន់តែធ្វើការបញ្ជាក់ថា ចង់បានប្រចាំខែ ត្រីមាស ឆមាស ឬឆ្នាំ នឹងត្រូវបញ្ជូនដោយក្រុមការងាររបស់ក្រសួង

យុត្តិធម៌ បើតួលេខមានបញ្ហាមិនត្រូវគ្នា យើងអាចជួបជជែកគ្នាបាន ។ **ឯកឧត្តម** បានលើកឡើងអំពីការស៊ើបអង្កេតសម្ងាត់ UIA ដែលបានជួបជាមួយស្ថានទូតអាមេរិកនៅក្រសួងមហាផ្ទៃ ក៏បានលើករឿងនេះមកពិភាក្សាដែរ ដែលត្រូវរក្សាបាននូវការគោរពសិទ្ធិបុគ្គលឯកជន និងត្រូវស្របតាមក្របខណ្ឌច្បាប់ នីតិវិធី នៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវមានគម្រោង និងមានគោលការណ៍ណែនាំជាក់លាក់ណាមួយថាត្រូវធ្វើក្នុងកម្រិតណា? ធ្វើយ៉ាងដូចម្ដេច? **ឯកឧត្តម** បានរំលឹកឡើងថា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏បានលើកឡើងដែរនៅក្នុងកិច្ចប្រជុំដែលមានសម្ដេចក្រឡាហោមជាអធិបតី លោកបានលើកឡើងថា ក្នុងករណីចាំបាច់ស្នើឲ្យមានការស៊ើបអង្កេតសម្ងាត់ណាមួយ គួរខាង FBI ត្រូវមានការពិភាក្សាជាមួយក្រសួងយុត្តិធម៌ និងអគ្គស្នងការនគរបាលជាតិជាមុនសិន ក្រោយមកក៏មានការបញ្ជាក់លើកទី២ ក្នុងជំនួបស្ថានទូតសហរដ្ឋអាមេរិក និងក្រសួងយុត្តិធម៌ លោកប្រធានក្រុមការងារ FBI ក៏បានមកចូលរួមដែរ ដែលពេលនោះ ឯកអគ្គរដ្ឋទូតក៏បានលើកឡើងអំពីការស៊ើបអង្កេតសម្ងាត់នេះផងដែរ ឯកឧត្តមរដ្ឋមន្ត្រីក៏បានលើកឡើងចំពោះមុខឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងលោកប្រធានក្រុម FBI ថាចំពោះការងារនេះមិនមែនកម្ពុជាមិនចង់ធ្វើ ឬរារែកអ្វីទាំងអស់ តែបើ FBI ចង់ស៊ើងអង្កេតណាមួយត្រូវជួបជាមួយខាងក្រសួង និងអគ្គស្នងការដ្ឋាននគរបាលជាតិជាមុនសិន ថាត្រូវធ្វើដោយរបៀបណា? បុគ្គលណាជាអ្នកមានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត? ហើយមានយន្តការគ្រប់គ្រងដោយរបៀបណា? ចាប់ពីពេលនោះមកខាងស្ថានទូតអាមេរិក និងFBI ហាក់ដូចជាស្ងាត់មិនមានសកម្មភាពអ្វីបន្ត ក្នុងការងារនេះកម្ពុជារីករាយនឹងសហការ ។ **ឯកឧត្តម** បានបញ្ជាក់ថា តាមការពិនិត្យឃើញថ្មីៗនេះខាងអគ្គស្នងការដ្ឋាននគរបាលជាតិក៏មានការចុះអនុស្សរណៈជាមួយ FBI ផងដែរ ដូច្នេះបើគាត់ចង់និយាយរឿងនេះ គឺមកក្នុងភាពជាដៃគូ មិនមែនថាកម្ពុជាមិនបើកចំហរនោះទេ ។ **ឯកឧត្តម** មានប្រសាសន៍បន្តថា កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ខាងសហរដ្ឋអាមេរិកបានផ្ញើអនុសាសន៍ចំនួន១៧ ចំណុចថ្មី សម្រាប់ឆ្នាំ២០២០ និង ២០២១ មកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយបានផ្ញើបន្តមកខាងក្រសួងយុត្តិធម៌ ពិនិត្យឃើញថាមានចំណុចខ្លះជាន់គ្នា និងមានចំណុចខ្លះថ្មី ក្នុងនោះក្រសួងយុត្តិធម៌ជាប់ការងារចំនួន ២ ដដែល ។

**លោកជំទាវ** ប្រធានអង្គប្រជុំ បញ្ជាក់ថា គឺយើងមិនបានបិទទេ គ្រាន់តែយើងបានបានអំពីទំហំ គម្រោង និងគោលនយោបាយច្បាស់លាស់ តើគាត់ចង់បានអ្វីឲ្យប្រាកដ? ព្រោះយើងបានពិភាក្សាគ្នាច្រើនឆ្នាំមកយើងអំពីបញ្ហា UIA នៅតែមិនយល់គ្នា ហើយសហរដ្ឋអាមេរិកបានជ្រើសរើសយកចំណុចនេះមកធ្វើការវាយតម្លៃ ដូច្នេះឆ្នាំនេះយើងនឹងពិភាក្សាលើបញ្ហានេះជាមួយគាត់ឲ្យបានច្បាស់ ព្រោះកន្លងមកកម្ពុជាក៏បានធ្វើការលើករណីនេះដែរ យើងបានធ្វើការបើកចំហរហូតមានការបង្កើតឲ្យមានទីស្នាក់ការនៅក្នុងបរិវេណអគ្គស្នងការដ្ឋានជាមួយគ្នាទៀត តើគាត់ចង់បានអីទៀតពីយើង? ចំពោះបញ្ហាប្រមូលទិន្នន័យ គឺយើងបានបើកចំហរហើយ តែអ្វីដែលគេចង់បានប្រហែលជាគេចង់ពិនិត្យលើសំណុំរឿងដែលគេចង់ដឹង តែយើងមិនទាន់ដឹងថារឿងអីនៅឡើយទេ យើងត្រូវត្រៀមគ្រប់យ៉ាងពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ ។ ចំពោះបញ្ហាថវិកា តើយើងគួរឆ្លើយយ៉ាងណាពាក់ព័ន្ធនឹងការជួយជន

រងគ្រោះ? ហេតុអ្វីបានជាគាត់ត្រូវសួររឿងបញ្ហាថវិកា? គាត់មិនគួរសួររឿងនេះទេ ។ មួយទៀតទាក់ទងនឹងការតាមដានអ្នកពាក់ព័ន្ធដែលនៅក្រៅឃុំតើភាពប្រឈមយើងយ៉ាងម៉េចដែរ?

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានលើកឡើងថា ទាក់ទងនឹងបញ្ហាថវិកានេះយើងមិនអាចឆ្លើយជាមួយគាត់បានទេ ព្រោះជាកិច្ចការផ្ទៃក្នុងរបស់យើង ចំពោះកិច្ចសហការយើងនៅតែបន្តសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ ទោះក្នុងកម្រិតណាក៏ដោយជាមួយអង្គការអន្តរជាតិនានា ដែលគាត់បានប្រើប្រាស់ឲ្យសហការជាមួយយើងដើម្បីទទួលបានទិន្នន័យពីយើង ។ **ឯកឧត្តម ឧត្តមសេនីយ៍ឯក** សូមគាំទ្រនូវប្រសាសន៍លើកឡើងរបស់ឯកឧត្តម រដ្ឋលេខាធិការក្រសួងយុត្តិធម៌ អំពីការស៊ើបអង្កេតសម្ងាត់ UIA ត្រូវមានការពិភាក្សាគ្នា ។ ចំពោះការតាមដាន គ្រប់គ្រងអ្នកពាក់ព័ន្ធដែលនៅក្រៅឃុំ គឺមិនមានបញ្ហាសម្រាប់មន្ត្រីនគរបាលយុត្តិធម៌យើងទេ ទាំងមន្ត្រីជំនាញនាយកដ្ឋាន រាជធានី ខេត្ត គឺមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដានឃ្លាំមើល ឬស្វែងរកជនប្រព្រឹត្តបទល្មើស ចំណែកថវិកាក៏មិនមានការចំណាយច្រើនអីដែរ តែក្នុងករណីខ្លះក៏ត្រូវមានការចំណាយថវិកាផងដែរ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍ថា មានចំណុចដែលយើងគិតថា ទី១.មិនឆ្លើយ ទី២.ឆ្លើយតែត្រូវឆ្លើយត្រឹមកម្រិតណាមួយ ដូចជាការជួយឧបត្ថម្ភជាសម្ភារៈ ប្រេង របស់ផ្សេងៗទៀតអាស្រ័យលើថវិកាជាតិថវិការបស់ក្រសួង ស្ថាប័ន តែគេសួរថាប៉ុន្មាន? គឺមិនអាចឆ្លើយបានទេ ព្រោះយើងមិនអាចប្រៀបធៀបថវិកាកម្ពុជាជាមួយថវិការបស់អាមេរិកទេ គឺយើងមានលទ្ធភាពតាមអ្វីដែលយើងមាន ដូច្នេះយើងគិតអាចរកចម្លើយខ្លះទៅពាក់ព័ន្ធនឹងថវិកានេះ ជាជាងយើងមិនធ្វើការឆ្លើយតប ។ ចំពោះការគ្រប់គ្រង តាមដានជននៅក្រៅឃុំ មានន័យថាយើងមានធនធានមនុស្សគ្រប់គ្រាន់ និងមាននីតិវិធីច្បាស់លាស់សម្រាប់ការអនុវត្តទៅតាមបណ្ដាញរបស់យើង តែមានការលើកឡើងថាមានបាត់ដានជនសង្ស័យ ឬជនដែលពាក់ព័ន្ធនៅក្រៅឃុំ ពេលគេសួរខាងយើងឆ្លើយថាមកពីការខ្វះថវិកា អាចឆ្លើយបានទេ? យើងត្រូវពង្រឹងនីតិវិធី នៃការបញ្ជូន និងទទួលឲ្យបានត្រឹមត្រូវលើមុខសញ្ញាដើម្បីធ្វើការតាមដានបន្ត និងមានរបាយការណ៍ជាក់លាក់ជៀសវាងការឆ្លើយដាក់គ្នា ។ មួយទៀតពាក់ព័ន្ធដំណើរការរឿងក្ដីចំពោះជនរងគ្រោះជាជនបរទេសមានសិទ្ធិក្នុងការធ្វើការងារ ឬផ្ដល់ការអនុញ្ញាតក្នុងការរស់នៅបណ្ដោះអាសន្ន ឬផ្ដល់ភាពងាយស្រួលណាមួយចំពោះគាត់? តើមានគោលការនេះអត់?

**ឯកឧត្តម ជីវ ផល្លី** បានលើកឡើងបន្ថែមថាទាក់ទងនឹងករណីបាត់ជនពាក់ព័ន្ធដែលនៅក្រៅឃុំ គឺមិនមែនមកពីបញ្ហាខ្វះខាតថវិកាទេ គឺមកពីបញ្ហាបច្ចេកទេស ដែលមន្ត្រីពាក់ព័ន្ធអនុវត្តការងារមិនបានស៊ីសង្វាក់គ្នា បញ្ហានេះយើងបានផ្ដល់ព័ត៌មានទៅអ្នកពាក់ព័ន្ធទាំងអស់តាមគោលដៅ ឬតាមបណ្ដារាជធានី ខេត្តនានា ករណីនេះគឺជាការធ្វេសប្រហែសមួយមានតែរឿងពពោះជំនួសទេ ក្រៅពីនេះគឺមិនមានបញ្ហាអ្វីទេ ។ ចំពោះការពាក់ព័ន្ធនឹងដំណើរការរឿងក្ដីរបស់ជនរងគ្រោះជាជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា គឺយើងបានកំណត់អត្តសញ្ញាណដោយពិនិត្យលើស្ថានភាព ផ្ដល់សេវាដែលពិធីសារប៉ាឡឺម៉ូបានចែង និងពិនិត្យលើលិខិតឆ្លងដែន ទិដ្ឋាការ ដូចជា

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើការលើកលែងការផាកពិន័យលើជនជាតិនេប៉ាល់ ២២ នាក់ ចំពោះបញ្ហាហួសសុពលភាពការស្នាក់នៅ និងមានករណីជនជាតិឥណ្ឌា បានរកឃើញថាជាជនរងគ្រោះដោយអំពើជួញដូរ ហើយបានស្នើសុំមកក្រសួងមហាផ្ទៃ សូមឲ្យ **សម្តេចក្រឡាហោម** លើកលែងចំពោះការផាកពិន័យ គឺយើងអាចធ្វើបាន តែចំពោះបញ្ហាថវិកាទាក់ទងការជួយ គឺត្រូវពឹងផ្អែកពីអង្គការដៃគូពាក់ព័ន្ធ ។ យើងក៏បានសម្រួលឲ្យមានភាពងាយស្រួលសម្រាប់ពួកគាត់ដោយមានជម្រើសសម្រាប់គាត់ តើគាត់ចង់ស្នាក់នៅកម្ពុជា ឬចង់ទៅប្រទេសខ្លួនវិញអំឡុងពេលដំណើរការរឿងក្តីនៅតុលាការ បើគាត់ចង់នៅយើងនឹងរៀបចំជូនគាត់ដោយសហការជាមួយដៃគូពាក់ព័ន្ធ តែបើគាត់ចង់ត្រឡប់ទៅប្រទេសគាត់វិញ គឺយើងនឹងធ្វើការទំនាក់ទំនងទៅស្ថានទូត ឬស្ថានតំណាងរបស់គាត់ដើម្បីធ្វើការធានាក្នុងការមកបង្ហាញមុខ ឬមកឆ្លើយបំភ្លឺជាមួយតុលាការនៅកម្ពុជាតាមការកោះហៅ ។

**ឯកឧត្តម ហ៊ូ ឌុន្នី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ពាក់ព័ន្ធនឹងដំណើរការរឿងក្តីនៅក្នុងតុលាការរបស់ជនបរទេស ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាថា បើជនបរទេសមិនទាន់ផុតសុពលភាពកិច្ចសន្យាការងារ គឺនៅតែបន្តធ្វើការងារដដែលរហូតដល់ខាងតុលាការសម្រេចយ៉ាងណា គឺត្រូវអនុវត្តតាមសាលដីការបស់តុលាការ ហើយយើងក៏បានលើកលែងចំពោះការលើសសុពលភាព នៃទិដ្ឋាការផងដែរ តែយើងមិនបានផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់គាត់ទេ និងផ្តល់ការអនុញ្ញាតការស្នាក់នៅរហូតដំណើរការក្តីត្រូវបានបញ្ចប់ ។ **ឯកឧត្តម** មានប្រសាសន៍លើកឡើងអំពីការអនុវត្តការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កន្លងមកថ្មីៗនេះស្ថានទូតអាមេរិកបានផ្ញើអនុសាសន៍ចំនួន១១ចំណុចថ្មី មកក្រសួងការងារ ដែលក្នុងនោះមានការពាក់ព័ន្ធចំនួន២ ចំណុចហើយយើងក៏បានអនុវត្ត ក្រសួងក៏បានចុះធ្វើអធិការកិច្ចទៅលើសិប្បកម្មឡឥដ្ឋ ផ្អែកនេសាទ លប់បំបាត់ការយកពន្ធពីពលករ ដែលបានសហការជាមួយអង្គការ IOM ដែលបានរកឃើញប្រព័ន្ធថ្មីមួយគឺតម្រូវឲ្យក្រុមហ៊ុនមិនយកកម្រៃពីពលករ ឬយកតិចបំផុត ដូចកាលពីមុនតម្រូវឲ្យពលករបង់ចំនួន២១ជំពូក ឥឡូវតម្រូវឲ្យបង់តែ២ ឬ៣ ជំពូកទេ ចំណែកនៅសល់ប៉ុន្មានជំពូកទៀតតម្រូវឲ្យនិយោជកជាអ្នកបង់ សូមបញ្ជាក់ផងដែរថាប្រព័ន្ធនេះមិនមែនជាប្រព័ន្ធចាប់បង្ខំទេ គឺជាប្រព័ន្ធស្ម័គ្រចិត្ត ដោយយើងបានធ្វើការងារនេះបានចំនួន១ឆ្នាំហើយ យើងនឹងអនុវត្តការងារនេះបន្តទៀត ហើយនឹងធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដោយសារការរីករាលដាល នៃជំងឺកូវីដ-១៩ ធ្វើឲ្យដំណើរការនេះមានការរាំងស្ទះបន្តិចបន្តួច តែយើងនឹងធ្វើបន្តនៅក្នុងខែមករា កុម្ភៈ ឆ្នាំ២០២១ ខាងមុខនេះ ។ **ឯកឧត្តម** បានលើកឡើងអំពីការធ្វើវិសោធនកម្មច្បាប់របស់យើង ក្រោយពីបានសហការគ្នារវាងអន្តរក្រសួង ស្ថាប័ននានា ក៏ដូចជាអង្គការដៃគូជាតិ អន្តរជាតិនានា យើងបានអនុវត្តការងារមួយចំនួន តែក៏សង្កេតឃើញមានចំណុចខ្វះខាតមួយចំនួនតែត្រូវធ្វើការកែលម្អ ដូច្នេះយើងត្រូវពិភាក្សាគ្នាដើម្បីធ្វើការកែសម្រួលនូវបទបញ្ញត្តិផ្សេងៗទាក់ទងទៅនឹងការដាក់ទោសទណ្ឌជនល្មើស ។ យើងក៏ត្រូវតែពង្រឹងដល់ទីភ្នាក់ងារជ្រើសរើស ដោយសហការជាមួយអង្គការ IOM និងអង្គការ ILO និងត្រូវធ្វើជាមួយវិស័យឯកជន និងសហជីព ដោយកាត់បន្ថយការចុះធ្វើអធិការកិច្ចដោយ ធ្វើបញ្ជីឈ្មោះ(Checklist) ក្រុមហ៊ុនឲ្យបានត្រឹមត្រូវច្បាស់លាស់ ដើម្បីបង្កើតឲ្យមានក្រមសីលធម៌ ហើយអង្គការ IOM និងអង្គការ ILO ក៏ត្រូវមានបញ្ជីឈ្មោះក្រុមហ៊ុនផ្ទាល់ខ្លួនផងដែរ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ តើក្រសួង ស្ថាប័ន អង្គភាពណាជាអ្នកទទួលខុសត្រូវឧបត្ថម្ភជនរងគ្រោះក្នុងនីតិវិធីតុលាការ? ដូចជាករណីជនរងគ្រោះនៅតាមខេត្តហើយត្រូវឡើងមកបង្ហាញមុខ ឬចូលបំភ្លឺក្នុងដំណាក់កាលតុលាការយូរៗទៅគ្មានលទ្ធភាពក្នុងការធ្វើដំណើរពីខេត្តមកដោះរឿងក្តីនៅភ្នំពេញ(ខ្វះថវិកា) ឥឡូវបានលេចលឺថា រាជរដ្ឋាភិបាលយើងមិនមានការចំណាយលើបញ្ហាទាំងនេះទេ គឺពឹងផ្អែកលើអង្គការដើម្បីធ្វើការងារនេះ ។ បើមានរឿងនេះតើអ្នកណាជាអ្នកទទួលខុសត្រូវ? លោកជំទាវ បញ្ជាក់ថា គេពិតជាដឹងថាយើងបានពឹងពាក់លើអង្គការដៃគូ តែគេចង់ជំរុញឲ្យរាជរដ្ឋាភិបាលទទួលខុសត្រូវទៅលើវិស័យនឹង ពីព្រោះបញ្ហានេះនឹងមានជាបន្តបន្ទាប់ទៀត តើយើងត្រូវពឹងផ្អែកលើអង្គការដៃគូពាក់ព័ន្ធដល់ពេលណា? រាជរដ្ឋាភិបាលកម្ពុជាក៏បានយកចិត្តទុកដាក់ខ្លាំងចំពោះការងារនេះផងដែរ ដូចជាការបង្កើតក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ ក្នុងការជួយដោះស្រាយរឿងក្តីដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនរងគ្រោះដែលខ្វះលទ្ធភាពតវ៉ារឿងក្តីតាមនីតិវិធី ។ យើងនៅមានការខ្វះខាតជាច្រើនទៀតដូចជាខ្វះខាតមណ្ឌលសម្រាប់ជនរងគ្រោះ ជនវិលត្រឡប់ គេថាយើងពឹងផ្អែកលើមណ្ឌលរបស់អង្គការ ដូច្នេះយើងគួរមានមណ្ឌលខ្លួនឯងជាគំរូ សម្រាប់ធ្វើការទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ **លោកជំទាវ** បានបញ្ជាក់ថា នៅពេលដែលធ្វើរបាយការណ៍ទៅគេ ត្រូវបញ្ជាក់អំពីគោលការណ៍ឲ្យបានច្បាស់លាស់ដើម្បីងាយស្រួលធ្វើការឆ្លើយតបទៅគេ ពីការរីកចម្រើនការងាររបស់យើង ។

**លោកស្រី ព្រុំ សុខន** ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការជួយឧបត្ថម្ភជនរងគ្រោះ ក្នុងដំណាក់កាលនីតិវិធីតុលាការ គឺជាការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយយើងបានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ ព្រោះថវិកាយើងមានកំណត់ តែក្រសួងក៏បានត្រៀមលក្ខណៈផងដែរចំពោះបញ្ហានេះ ។

**ឯកឧត្តម ខេង ហៀង** អគ្គនាយក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពាក់ព័ន្ធនឹងការងារនេះ គឺយើងមានវឌ្ឍនភាពច្រើនព្រោះយើងបានធ្វើការងារនេះយូរឆ្នាំមកហើយ ។ យើងបានបញ្ជូនកុមារទៅធ្វើការបណ្តុះបណ្តាលជាច្រើនពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ ហើយយើងបានចុះធ្វើអធិការកិច្ចជារៀងរាល់ឆ្នាំ ប៉ុន្តែយូរក៏មានឧបទ្ទវហេតុម្តងដោយសារការធ្វេសប្រហែសរបស់ឪពុកម្តាយ និងនិយោជក ។ យើងពិនិត្យឃើញថានៅតាមសិប្បកម្មឡឥដ្ឋភាគច្រើនគឺខ្វះអនាម័យ ទឹកស្អាត កន្លែងស្នាក់នៅរបស់កម្មករជាដើម បន្ទាប់មកក្នុងឆ្នាំ២០១៦ យើងបានរឹតបន្តឹងការចុះធ្វើអធិការកិច្ចលើសិប្បកម្មឡឥដ្ឋ ក្រុមហ៊ុន សហគ្រាស ដូចជាការផ្តល់កន្លែងស្នាក់នៅ ប្រាក់ឈ្នួលមានការកើនឡើង និងបញ្ហាសុខភាពអនាម័យថៅកែមានការយល់ដឹងច្រើន ហើយថៅកែភាគច្រើនជួយកូនកម្មករឲ្យបានចូលសាលារៀន តែអ្វីដែលជាការព្រួយបារម្ភ របស់យើងក្នុងឆ្នាំ២០១៨ ២០១៩ គឺបញ្ហាទិដ្ឋភាពបំណុល ដែលជាបញ្ហាជំពាក់បុគ្គល និងស្ថាប័នមីក្រូហិរញ្ញវត្ថុ មិនមែនជំពាក់ថៅកែទេ ។ មកដល់ពេលនេះក្នុងឆ្នាំ២០២០ យើងបានធ្វើការកំណត់ចុះបញ្ជីមានសិប្បកម្មឡឥដ្ឋចំនួន ៤០០ កន្លែង មានទំហំធំជាងមុនជាង១០ដង ដែលមានចំនួនកម្មករជាង៧ពាន់នាក់ ដែលពីមុនមានចំនួនត្រឹមតែ២ពាន់នាក់ប៉ុណ្ណោះ និងមានការរីកចម្រើនផ្នែកប្រព័ន្ធទំនើបកម្មជាងមុន តែនៅមានចំនួនតិចតួចនៅឡើយ តែដោយសារការរីករាលដាលជំងឺកូវីដ-១៩ ធ្វើឲ្យមានការ អាក់ខាន នៃ

ការបញ្ជូនកុមាររងគ្រោះមានចំនួនជា៤០០នាក់ ដែលក្រសួងបានជួយឧបត្ថម្ភក្នុងការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ឲ្យមានការចូលរៀន សម្ភារៈសិក្សា និងថវិកាផងដែរ យើងក៏មានការផ្សព្វផ្សាយទូលំទូលាយផងដែរ អំពីការដាក់ទោសទណ្ឌចំពោះបទល្មើសជួញដូរមនុស្ស ជាពិសេសការជួញដូរកម្លាំងពលកម្មកុមារ ។ ឯកឧត្តម បានបញ្ជាក់ថា អាមេរិកប្រហែលជាដកឃ្លាពីការតាមដានលើសិប្បកម្មឡឥដ្ឋ ងាកទៅរកលើវិស័យនាំចេញសាច់គោ និងចំការអំពៅ ក្រសួងការងារអាមេរិកបានស្នើសុំឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្ញើរបាយការណ៍អំពីការសង្គ្រោះ ការបណ្តុះបណ្តាល ជួយជនរងគ្រោះ ជាពិសេសកុមារ ក្រសួងកំពុងរៀបចំដើម្បីផ្ញើទៅអាមេរិកប្រហែលក្នុងខែមករា ឆ្នាំ២០២១ នេះ ក្នុងករណីនេះនឹងស្នើឲ្យមានការសហការពីក្រសួងពាក់ព័ន្ធ ជាពិសេសគឺក្រសួងកសិកម្ម ។ ចំពោះបញ្ហាវិស័យនេសាទ គឺមិនមានអ្វីជាបញ្ហាចោទទេចំពោះការប្រើប្រាស់កម្លាំងកុមារ តែចំពោះការព្រួយបារម្ភ គឺកន្លែងកែឆ្នៃផលិតផលនេសាទ បកក្តាម បង្គារជាដើម ចំពោះសិប្បកម្មស្រែអំបិលគឺយើងលែងមានហើយ ដូច្នេះគឺគ្មានអ្វីគួឲ្យព្រួយបារម្ភទេ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍អំពីការប្រមូលទិន្នន័យ នីតិវិធី នៃការប្រមូលទិន្នន័យចំពោះជនរងគ្រោះដែលបានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប៉ុន្មាននាក់? មន្ត្រីបានប៉ុន្មាននាក់ តើពួកគាត់បានធ្វើអ្វីខ្លះ? នៅកន្លែងណា? បញ្ហាមួយទៀត គឺសេវាជួយជនរងគ្រោះជាបុរសពេលគេបញ្ជូនមកវិញ ឬត្រឡប់មកវិញដោយខ្លួនឯង តើត្រូវឆ្លើយយ៉ាងម៉េច? យើងធ្វើបានអ្វីខ្លះ? សុំឲ្យមានជារបាយការណ៍ ស្តីពីជនរងគ្រោះ និងជនងាយរងគ្រោះ? ការទទួលបានសំណងបដិទានក្នុងអំឡុងពេលដំណើរការក្តីរបស់តុលាការ? លោកជំទាវ ស្នើសុំឲ្យមានជារបាយការណ៍ជាក់លាក់អំពីបញ្ហានេះ ។

**លោកស្រី ព្រុំ សុខន** ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានលើកឡើងថា ក្រសួងបានធ្វើការបណ្តុះបណ្តាលថ្នាក់មូលដ្ឋានដល់មន្ត្រីជំនាញជួរមុខបានចំនួន ៥ នាក់ ក្នុងរយៈពេល ១ឆ្នាំ ដែលជាចំនួនតិចតួច តែក្រសួងនឹងអនុវត្តបន្តលើការងារបណ្តុះបណ្តាលនេះ ។

**ឯកឧត្តម កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ មានប្រសាសន៍ទាក់ទងនឹងការទទួលសំណងបដិទាន អំឡុងពេលដំណើរការរឿងក្តីរបស់តុលាការគឺមានទិដ្ឋភាព២ ទី១.គឺជាសំណងដែលជនល្មើសត្រូវបានសម្រេចដោយសាលក្រមតុលាការ និងតម្រូវឲ្យសងសំណងបដិទានដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ចំពោះសំណងបដិទាន គឺគិតទៅលើអ្វីដែលជាអតីតកាល ដូចជាជនរងគ្រោះធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋមួយកន្លែងដែលគាត់ត្រូវទទួលបានប្រាក់ខែ២០០ដុល្លារ តែថៅកែឡឥដ្ឋផ្តល់ឲ្យគាត់តែ១០០ដុល្លារទេ ក្នុង១ខែ រហូតរយៈពេល៥ឆ្នាំ ដូច្នេះថៅកែត្រូវសងសំណងបដិទានទៅគាត់ឲ្យគ្រប់តាមចំនួនដែលគាត់បានធ្វើការនៅទីនោះ តែចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺមិនមានការកំណត់ឲ្យជនត្រូវចោទសងសំណងបដិទានទៅជនរងគ្រោះតាមអតីតកាលទេ គិតតាមច្បាប់នៅកម្ពុជាតម្រូវឲ្យជនរងគ្រោះស្នើទាមទារសំណង ដើម្បីប៉ះប៉ូវការខូចខាតណាមួយ ហើយជនល្មើសត្រូវទទួលបន្ទុកសងទៅតាមការសម្រេចរបស់តុលាការ ប៉ុន្តែបើជនល្មើសគាត់គ្មានលទ្ធភាព

គ្រីក្រដែរ ដូច្នេះតាមក្រម នៃព្រះរាជាណាចក្រកម្ពុជាតម្រូវបង្ខំឲ្យជនល្មើសជាប់ពន្ធនាគាររយៈពេល២ឆ្នាំបន្ថែមទៀត នេះជាផលលំបាកមួយ នៃទិដ្ឋភាពច្បាប់ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ ពាក់ព័ន្ធការត្រៀមបម្រុងធនធានមនុស្សសម្រាប់អនុវត្តនីតិវិធី ដើម្បីជួយជនរងគ្រោះជាជនជាតិខ្មែរ រួមទាំងក្នុងប្រទេសដែលគ្មានតំណាងស្ថានទូតនៅទីនោះនៅក្រៅប្រទេស តើក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មាននិតិវិធីយ៉ាងណាចំពោះបញ្ហានេះ?

**លោក ជ័យ រដ្ឋា** ប្រធាននាយកដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើការបំភ្លឺពាក់ព័ន្ធអនុសាសន៍ទី១៣ ស្តីពីការត្រៀមបម្រុងធនធានមនុស្សសម្រាប់អនុវត្តនីតិវិធី ដើម្បីជួយជនរងគ្រោះជាជនជាតិខ្មែរនៅក្រៅប្រទេស ។ លោក បានលើឡើងអំពីជនជាតិនេប៉ាល់២២នាក់ យើងបានជួបប្រជុំគ្នាម្តងរួចហើយនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏មានការលើកឡើងអំពីបញ្ហានេះផងដែរ ខាងក្រសួងការបរទេសក៏បានទាក់ទងទៅស្ថានទូតកម្ពុជានៅប្រទេសនេប៉ាល់ គេក៏បានផ្តល់ព័ត៌មានមកថា ប្រជាជនទាំងនេះមកតាមរយៈក្រុមហ៊ុននេប៉ាល់ និងក្រុមហ៊ុនខ្មែរយើងមួយ បន្ទាប់មកក៏បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន និងបានឲ្យខាងនេប៉ាល់ទាក់ទងមកខាងក្រសួងមហាផ្ទៃ ដើម្បីប្តឹងក្រុមហ៊ុននាំមក តែនីតិវិធីនេះមិនដឹងដំណើរការយ៉ាងណាទេ គឺគ្រាន់តែដឹងថាជួយឲ្យជនជាតិនេប៉ាល់២២នាក់ បានត្រឡប់ទៅវិញ និងមិនឲ្យមានការផាកពិន័យលើការស្នាក់នៅហួសកំណត់ ដោយមានការសម្របសម្រួលពីក្រសួងមហាផ្ទៃ ជនជាតិនេប៉ាល់២២នាក់បានចាកចេញនៅល្ងាចថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០នេះ តាមរយៈជើងយន្តហោះសាំងហ្គាពួរ ។ ពាក់ព័ន្ធអនុសាសន៍ទី១៣ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រឹងប្រែងណាស់ក្នុងការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ដែលកន្លងមកក្នុងហាការកសាងធនធានមនុស្សលើការបណ្តុះបណ្តាលធនធានមនុស្សអំពីការប្រឆាំងជួញដូរមនុស្ស និងការជួយជនរងគ្រោះនៅក្រៅប្រទេស ហើយនៅឆ្នាំក្រោយក្រសួងនឹងមានបើកវគ្គបណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រីការទូតជំនាន់ក្រោយ ដោយមានការបណ្តុះបណ្តាលពីមន្ត្រីស្ថានទូតចាស់ៗ ដែលជារៀមច្បង និងមានការចង្អុលបង្ហាញ តម្រង់ទិស ផ្តល់បទពិសោធន៍ជាលាយល័ក្សអក្សរ ពីការងារការទូតនៅក្រៅប្រទេស និងការងារជួយជនរងគ្រោះពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅក្រៅប្រទេស ហើយក្រសួង ក៏បានចងក្រងជាឯកសារសម្រាប់បង្រៀនដល់មន្ត្រីដែលត្រូវទៅកាន់មុខតំណែងនីមួយៗនេះផងដែរ ។ លោក បានបញ្ជាក់ថា នៅក្នុងឆ្នាំ២០២១ ខាងមុខនេះ ខាងក្រសួងនឹងមានរៀបចំវគ្គបំពាក់បំប៉នបន្ថែមដល់មន្ត្រីការទូត ឯកអគ្គរាជទូត និងមន្ត្រីពាក់ព័ន្ធទាំងអស់ នៃក្រសួងការបរទេស ដែលត្រូវបំពេញបេសកកម្មនៅតាមបណ្តាប្រទេសនានា ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ ប្រធានអង្គប្រជុំ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានបទពិសោធន៍នឹងការជួញដូរមនុស្ស និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមក្រសួង ស្ថាប័ននីមួយៗ ឲ្យកាន់តែយល់ដឹងកាន់តែជ្រៅជ្រះជាងនេះ ។ លោក បានបញ្ជាក់ថា សម័យកាល នៃជំងឺកូវីដ-១៩ បានរីរាលដាលនៅក្នុងពិភពលោក សង្កេតឃើញថានៅតែមានការលួចចេញទៅក្រៅប្រទេសជាពិសេសប្រទេសចិនដោយឆ្លងកាត់ប្រទេសវៀតណាម មិនដឹងថាត្រូវបញ្ជ្រាបការយល់ដឹងបែបណាទៅដល់ពួកគាត់ទេ ដោយសារបញ្ហា

នេះទើប ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស សម្រេចបង្កើតស្ថានតំណាងចំនួន២ ក្នុងឆ្នាំ ២០២០ នេះ នៅប្រទេសចិន ។ ស្ថានទូត ស្ថានកុងស៊ុលយើង គឺគាត់បានខិតខំប្រឹងណាស់ក្នុងការសហការជាមួយ បណ្តាប្រទេសជាមិត្តទាំងនៅក្នុងអាស៊ាន និងប្រទេសក្នុងតំបន់អឺរ៉ុប ហើយក៏មានប្រជាជនខ្មែរយើងទៅដល់អាហ្វ្រិក ផងដែរ យើងក៏បានទំនាក់ទំនងជួយត្រឡប់មកវិញ ។ ទាក់ទងនឹងបញ្ហាថវិកា គឺមានការខ្វះខាតដូចក្រសួងនានាដែរ តែ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានដកថវិកា៥០% ពី ស្ថានតំណាងប្រចាំនៅប្រទេសផ្សេងៗមកជួយដល់ប្រទេស ដែលមានពលកររស់នៅច្រើនដូចជា ប្រទេសថៃ ម៉ាឡេស៊ី កូរ៉េ ជាដើម និងបានស្នើសុំទៅរាជរដ្ឋាភិបាលមួយ ចំណែកផងដែរដើម្បីជួយគ្នាបន្ថែមទៀត ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានន័យថា យើងមានឆន្ទៈខ្លាំងក្លាដើម្បីមុខមាត់ប្រទេសជាតិយើង ។ ចំពោះការបណ្តុះបណ្តាលមន្ត្រីស្ថានទូត ស្ថានកុងស៊ុលបន្ថែម រីករាយនឹងចូលរួមក្នុងការចែករំលែកបទពិសោធន៍ ជូនតាមរយៈការអញ្ជើញរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ លោកជំទាវ បានលើកឡើងអំពី ចំណុចទី១៦ បង្កើនការយល់ដឹងជាសាធារណៈ លើនីតិវិធី នៃការដាក់ស្នើសុំឯកសារធ្វើដំណើរដែលត្រឹមត្រូវដើម្បី សម្រួលដល់ការធ្វើទេសន្តរប្រវេសន៍មានសុវត្ថិភាព និងតាមផ្លូវច្បាប់ ។ បញ្ហានេះ មានពលករចេញទៅទាំងស្រប ច្បាប់ និងមិនស្របច្បាប់ ហើយគេនៅតែអាចរកការងារធ្វើបាននៅក្រៅប្រទេស នេះជាបញ្ហាខ្វះចន្លោះរបស់យើង ទោះបីយើងខំប្រឹងប្រែធ្វើការផ្សព្វផ្សាយ ទប់ស្កាត់យ៉ាងណាក៏ដោយ ដូច្នេះតើយើងត្រូវធ្វើការយ៉ាងដូចម្តេចដើម្បី គ្រប់គ្រងពួកគាត់បាន?

**ឯកឧត្តម ហ៊ូ ឲុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះករណីនេះខាង ក្រសួងសង្គមកិច្ច បានខិតខំធ្វើការផ្សព្វផ្សាយ ទូលំទូលាយណាស់ ទាំងមន្ត្រីពាក់ព័ន្ធ និងប្រជាពលរដ្ឋតាមគ្រប់ បណ្តាខេត្ត តែនៅតែមានអ្នកចេញទៅ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ ចំពោះការងារនេះ ក៏មានការពាក់ព័ន្ធនឹងប្រទេសគោលដៅដែរ ដែលធ្វើឲ្យ ពិបាកក្នុងការគ្រប់គ្រង ។ សូមឲ្យរំលេចអំពីវិធីសាស្ត្រថ្មីៗសម្រាប់ធ្វើការផ្សព្វផ្សាយក្នុងមួយឆ្នាំៗ ធ្វើនៅកន្លែងណា? ធ្វើបានប៉ុន្មានដង? ផ្សព្វផ្សាយតាមវិធីសាស្ត្រអ្វី? លើកពីប្រធានបទអីមកពន្យល់គាត់? បានសហការជាមួយ ស្ថាប័នណាខ្លះ? គិតថាអាចនឹងមានអ្នករត់ការក្រៅផ្លូវការពាក់ព័ន្ធការស្នើសុំឯកសារធ្វើដំណើរត្រឹមត្រូវ ។ ចំពោះ ចំណុចទី១៧ ពង្រឹងកិច្ចប្រឹងប្រែងដើម្បីដាក់បញ្ចូលអង្គការទៅក្នុងគោលនយោបាយ សម្រាប់ការផ្ទេរសិទ្ធិអាណា ព្យាបាល ជាផ្លូវការដល់ជនរងគ្រោះជាកុមារ ។ ចំណុចនេះ រាជរដ្ឋាភិបាល គឺបានសហការជាមួយអង្គការដៃគូជា ច្រើនទាំងជាតិ និងអន្តរជាតិ តាមរយៈការអញ្ជើញឲ្យមកចូលរួមកិច្ចប្រជុំពិគ្រោះយោបល់នានា វេទិកាសាធារណៈ ។ ចំពោះបញ្ហាទាក់ទងនឹងស្ថាប័នប្រាក់កម្ចី គឺពាក់ព័ន្ធខាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចុងបញ្ចប់ នៃកិច្ចប្រជុំពិភាក្សា **លោកជំទាវ** ប្រធានអង្គប្រជុំស្នើឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធចងក្រងរបាយ ការណ៍ច្បាស់លាស់ ជាក់លាក់ និងរកវិធីសាស្ត្រដើម្បីត្រៀមឆ្លើយតបជាមួយសហរដ្ឋអាមេរិកពាក់ព័ន្ធនឹងការងារ

ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ពីព្រោះកិច្ចប្រជុំពិភាក្សាថ្ងៃនេះយើងបានត្រឹមរំលេចអំពីវឌ្ឍនភាពខ្លះៗ នៃការងារការជួញដូរមនុស្សរបស់ក្រសួងពាក់ព័ន្ធ សង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងត្រៀមជារបាយការណ៍គន្លឹះសំខាន់ៗ និងការរីកចម្រើនការងារ នៃក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ផ្តល់ការឆ្លើយតបជាមួយស្ថានទូតអាមេរិកនាថ្ងៃខាងមុខ ។ **លោកជំទាវ** មានប្រសាសន៍លើកឡើងថា សព្វថ្ងៃនេះនៅទូទាំងពិភពលោកមានការចាប់អារម្មណ៍នឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទោះបីជាមានការរីករាលដាល នៃជំងឺកូវីដ-១៩ ក៏ដោយ ព្រោះអំពើជួញដូរមនុស្សនៅលើពិភពលោកហាក់បីដូចជាមិនថមថយឡើយ ។ **លោកជំទាវ** មានប្រសាសន៍ផ្តាំផ្ញើសូមឲ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការការពារពីការឆ្លង នៃជំងឺកូវីដ-១៩ តាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**លោកជំទាវ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន និងមន្ត្រីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមកិច្ចប្រជុំពិភាក្សានាពេលនេះ ។

កិច្ចប្រជុំបានបញ្ចប់វេលាម៉ោង ដប់ប្រាំមួយ និងសែសិបប្រាំនាទីល្ងាច ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

**សូមគោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់

ថ្ងៃព្រហ ២ រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២០

**អគ្គលេខាធិការ គ.ជ.ប.ជ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ

06/01/2021